# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## អគ្គនាយកដ្ឋានស្រាវជ្រាវ
## នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- មូលបត្របំណុលរដ្ឋកម្ពុជា ត្រូវបានរំពឹងថានឹងត្រូវបោះផ្សាយលក់នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ ខាងមុខ
- ការនាំចេញអង្ករកម្ពុជា នឹងងើបឡើងវិញជាមួយនឹងកំណើនជាង ១១% នៅឆ្នាំ២០២២ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា
- ឌីជីថលូបនីយកម្ម មានសារសំខាន់សម្រាប់ការបន្តសកម្មភាពអាជីវកម្មនៅកម្ពុជាអំឡុងវិបត្តិកូវីដ-១៩
- រោងចក្រផលិតសម្បកកង់ធំមួយរបស់ចិន គ្រោងបោះទុនវិនិយោគ ៣០០លានដុល្លារ សង់រោងចក្រនៅខេត្តព្រះសីហនុ
- សេចក្តីព្រាងច្បាប់ពាណិជ្ជកម្មសំខាន់ៗចំនួន៣ នឹងជួយស្តារសេដ្ឋកិច្ច និងសង្គមកម្ពុជាពីវិបត្តិកូវីដ១៩
- ឥណ្ឌូណេស៊ីនឹងលក់មូលបត្របំណុលជិត ១១ ប៊ីលានដុល្លារទៅឱ្យធនាគារកណ្តាលនៅចុងឆ្នាំ
- វៀតណាមព្យាយាមចាប់យកឱកាសសម្រាប់សេដ្ឋកិច្ចឌីជីថល
- កម្ពុជារំពឹងទទួលបានហិរញ្ញប្បទានឥតសំណងពីអាមេរិក ៣០០លានដុល្លារ នៅត្រីមាសទី១ឆ្នាំ២០២២
- អ្នកសេដ្ឋកិច្ចបានកាត់បន្ថយការព្យាករណ៍កំណើនសេដ្ឋកិច្ច របស់សហរដ្ឋអាមេរិកសម្រាប់ឆ្នាំ២០២២ ដោយសារ ការរាំងស្ទះនៃផែនការចំណាយរបស់រដ្ឋបាលប្រធានាធិបតី ចូ បៃដិន
- ការខ្ចីប្រាក់របស់ចក្រភពអង់គ្លេសបានធ្លាក់ចុះពាក់កណ្តាល ខណៈដែលការចំណាយលើជំងឺរាតត្បាតកូវីដ-១៩មានសភាពធូរស្រាល


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### មូលបត្របំណុលរដ្ឋរបស់កម្ពុជា ត្រូវបានរំពឹងថានឹងត្រូវបោះផ្សាយលក់នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២ ខាងមុខ



*ប្រភព៖ Khmer Times ២០២១*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលនៃការរៀបចំនីតិវិធីច្បាប់សម្រាប់ដំណើរការបោះផ្សាយលក់មូលបត្ររដ្ឋ ដែលមានទំហំទឹកប្រាក់ ៣០០លានដុល្លារអាមេរិក។ ក្រសួងនឹងធ្វើសេចក្តីប្រកាសជាសាធារណៈអំពីកាលបរិច្ឆេទផុតកំណត់ និងអត្រាការប្រាក់ ឬការទូទាត់គូប៉ុងនៃមូលបត្របំណុលរដ្ឋនេះបើយោងតាមប្រសាសន៍របស់ ឯកឧត្តម ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មូលបត្របំណុលរដ្ឋរបស់កម្ពុជា ត្រូវបានរំពឹងថានឹងត្រូវបោះផ្សាយនៅក្នុងត្រីមាសទី១ នៅឆ្នាំ២០២២ ខាងមុខ ដើម្បីកៀរគរប្រភពហិរញ្ញប្បទានសម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល និងរួមចំណែកក្នុងការពង្រឹងទីផ្សារមូលបត្រកម្ពុជាឱ្យកាន់តែរឹងមាំ ក៏ដូចជាបង្កើនដើមទុនពីវិស័យឯកជនឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។

ការបោះផ្សាយមូលបត្របំណុលរដ្ឋ គឺជាផ្នែកមួយនៃការកាត់បន្ថយការខ្ចីបុលពីបរទេស ដោយរាជរដ្ឋាភិបាលផ្តោតលើការកៀរគរប្រភពហិរញ្ញវត្ថុពីប្រភពក្នុងស្រុក ពីព្រោះនៅពេលដែលសេដ្ឋកិច្ចរបស់យើងរីកចម្រើនដល់កម្រិតជាក់លាក់មួយ ប្រភពនៃដើមទុនដែលយើងបានទទួលកាលពីអតីតកាលក្នុងទម្រង់នៃកម្ចីទ្វេភាគី ឬពហុភាគីនឹងត្រូវកាត់បន្ថយបន្តិចម្តងៗ ដូច្នេះយើងនឹងត្រូវការទីផ្សារមូលបត្រដើម្បីបង្កើនដើមទុនសម្រាប់គាំទ្រគម្រោងវិនិយោគសាធារណៈ នេះបើយោងតាមសម្តីរបស់លោក ហុង សុខហួរ អគ្គនាយកក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

សូមបញ្ជាក់ដែរថា ថវិកាដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលរដ្ឋ នឹងគាំទ្រគម្រោងវិនិយោគសាធារណៈប្រហែល ៣៥ ដែលបានលើកឡើងនៅក្នុងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២២ ក្នុងនោះរួមមាន៖ គម្រោងថាមពល ប្រព័ន្ធធារាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងវិស័យអាទិភាពផ្សេងៗទៀត។ ខណៈ ការបោះផ្សាយលក់មូលបត្របំណុលរដ្ឋ និងកម្ចីសម្បទានសម្រាប់ឆ្នាំ២០២២ នឹងមិនបង្កើតបន្ទុកបំណុលដល់កម្ពុជាឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានបញ្ជាក់ដែរថា ស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែមាននិរន្តរភាព និងហានិភ័យទាបជាមួយនឹងសូចនាករបំណុលសំខាន់ៗនៅក្រោមកម្រិតសូចនាកររៀងៗខ្លួន៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ Khmer Times ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១*

## ការនាំចេញអង្ករកម្ពុជា នឹងងើបឡើងវិញជាមួយនឹងកំណើនជាង ១១% នៅឆ្នាំ២០២២ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ KT/Chor Sokunthea*

ការនាំចេញអង្ករកម្ពុជា ត្រូវបានព្យាករណ៍ថានឹងកើនឡើងវិញដល់ ៧០០ ០០០តោន នៅក្នុងឆ្នាំ២០២២ ខាងមុខ ពោលគឺកើនឡើង ១១,១% ធៀបនឹងឆ្នាំ ២០២១ នេះ យោងតាមសម្ដីរបស់លោក Andy Lay អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា។

កម្ពុជា បាននាំចេញអង្ករចំនួន ៥៣០ ០០០តោន គិតត្រឹមខែវិច្ឆិកា នៃឆ្នាំ២០២១ និងត្រូវបានព្យាករណ៍ថានឹងមានចំនួន ៦៣០ ០០០តោន សម្រាប់ពេញមួយឆ្នាំ ២០២១។ តួលេខនេះគឺធ្លាក់ចុះ ៨,៧% ធៀបនឹងឆ្នាំ ២០២០ ដែលមានចំនួនសរុប ៦៩០ ០០០តោន។

លោក Andy Lay បានបញ្ជាក់ថាទីផ្សារសំខាន់ៗ សម្រាប់ការនាំចេញអង្កររបស់កម្ពុជា គឺប្រទេសនៅក្នុងសហភាពអឺរ៉ុប ខណៈដែលប្រទេសចិននឹងនៅតែដើរតួនាទីចម្បងក្នុងការនាំចេញក្នុងបរិមាណខ្ពស់។

ប៉ុន្តែ លោក Andy Lay បានបញ្ជាក់ថាការកើនឡើងនៃថ្លៃដឹកជញ្ជូនដោយសារការបិទព្រំដែន និងការកើនឡើងនៃជំងឺរាតត្បាតកូវីដ-១៩ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប ជាមួយនឹងការត្រលប់មកវិញនូវកុងតឺន័រទទេរ គឺជារឿងពិបាកណាស់។ ខណៈ បញ្ហាកង្វះកុងតឺន័រដែលមានទំហំសមស្រប បានប៉ះពាល់ដល់ការនាំចេញក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ និងទំនងជានឹងបន្តក្នុងរយៈពេលខ្លី ដែលយ៉ាងហោចណាស់នឹងចំណាយពេល ៦ខែទៀតដើម្បីឱ្យអ្វីៗត្រលប់មកវិញ ប៉ុន្តែមិនមែនត្រលប់មកធម្មតាទេ គឺគ្រាន់តែអាចសម្រួលស្ថានការណ៍ប៉ុណ្ណោះ។ លោកក៏បានបន្ថែមទៀតថា លោកយល់ស្របជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានអំពាវនាវឱ្យកម្ពុជាធ្វើទំនើបកម្មបច្ចេកវិទ្យាកសិកម្មរបស់ខ្លួន និងអប់រំកសិករពីរបៀបប្រើប្រាស់ឧបករណ៍ថ្មី ប៉ុន្តែលោកថាបញ្ហានេះនឹងនាំឱ្យមានបញ្ហាប្រឈមក្នុងរយៈពេលខ្លី។ ម៉្យាងវិញទៀត កម្ពុជាទំនងជាទទួលរងផលប៉ះពាល់កាន់តែខ្លាំងឡើងដោយគ្រោះរាំងស្ងួត និងទឹកជំនន់ដោយសារការប្រែប្រួលអាកាសធាតុ ដែលតម្រូវឱ្យកសិករត្រូវសម្របខ្លួនដើម្បីដោះស្រាយបញ្ហានេះ៕ *ដោយ ស៊ិន សុភារ៉*

*ប្រភព៖ Khmer Times ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១*

## ទំហំឥណទានក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុកើន ២៣% នៅត្រីមាសទី៣ឆ្នាំ២០២១



*ដោយ ខេមបុណ្ណមីស*

ទិន្នន័យពីធនាគារជាតិនៃកម្ពុជាបានបង្ហាញថា គិតត្រឹមត្រីមាសទី៣ឆ្នាំ២០២១ ទំហំឥណទានដែលផ្តល់ដោយធនាគារ និងមីក្រូហិរញ្ញវត្ថុ សម្រេចបានជិត ៤៥ ពាន់លានដុល្លារអាមេរិក កើនឡើង ២៣%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ នេះបានឆ្លុះបញ្ចាំងពីភាពរឹងមាំនៃវិស័យធនាគារ និងហិរញ្ញវត្ថុកម្ពុជា ទោះបីមានការរំខានពីការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ។

ភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុនេះគឺបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសធនាគារជាតិនៃកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រជាបន្តបន្ទាប់ឱ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុអនុវត្ត ដើម្បីជួយអតិថិជន ដែលរងផលប៉ះពាល់ដោយសារវិបត្តិកូវីដ-១៩។

តាមរយៈបទពិសោធន៍ ដែលគ្រឹះស្ថានហិរញ្ញវត្ថុបានឆ្លងកាត់ក្នុងអំឡុងនៃវិបត្តិកូវីដ-១៩កន្លងមក វានឹងជួយឱ្យវិស័យហិរញ្ញវត្ថុកម្ពុជាកាន់តែមានភាពធន់ និងរីកចម្រើនបន្ថែមទៀតនៅក្នុងឆ្នាំ២០២២ ខាងមុខ។ វិស័យហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារ និងជំរុញកំណើនក្នុងវិស័យផ្សេងៗ ជាពិសេសវិស័យសេដ្ឋកិច្ច។ ឥណទាននេះ គ្របដណ្តប់លើវិស័យសំណង់ កម្មន្តសាល កសិកម្ម សេវាកម្ម ការជួញដូរដុំ និងរាយ និងអង្គភាពគ្រួសារ ជាដើម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១។*

## ឌីជីថលូបនីយកម្ម មានសារសំខាន់សម្រាប់ការបន្តសកម្មភាពអាជីវកម្មនៅកម្ពុជាអំឡុងវិបត្តិកូវីដ-១៩




*ដោយ ខេមបូណ្ឌមីស*

យោងតាមរបាយការណ៍ក្រោមចំណងជើងថា «សហគ្រាសមីក្រូ ធុនតូច និងធុនមធ្យម និងការប្រើប្រាស់មុខងារឌីជីថលក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩» បានរកឃើញថា មុខងារឌីជីថលមានសារៈសំខាន់សម្រាប់អាជីវកម្ម នេះដោយសារកំណើននៃការប្រើប្រាស់ចេញពីគេហដ្ឋាន។ បច្ចុប្បន្នកំណើនអ្នកលេងអ៊ីនធឺណិតច្រើនជាងពេលមុន របៀបរស់នៅថ្មីរបស់អ្នកប្រើប្រាស់កំពុងលេចចេញឡើង ពោលគឺជាទម្លាប់ទិញថ្មី របៀបស្វែងរកថ្មី និងការរំពឹងទុកថ្មី។ លទ្ធផលនៃការស្ទង់មតិ បានបង្ហាញពីការកើនឡើងយ៉ាងខ្លាំងក្នុងការប្រើប្រាស់Facebook និងសារឆ្លើយឆ្លងដោយផ្ទាល់ (direct messaging) ដើម្បីប្រតិបត្តិការអាជីវកម្មនៅកម្ពុជា។

នាយកផ្នែកគោលនយោបាយសាធារណៈប្រចាំប្រទេសកម្ពុជារបស់ Facebook បានថ្លែងថា៖ «យើងបន្តផ្តោតការយកចិត្តទុកដាក់លើការពន្លឿនការស្ទុះងើបឡើងវិញនៅកម្ពុជា តាមរយៈការធ្វើកិច្ចការដែលប្រសើរបំផុតដែលយើងអាចធ្វើបាន ដោយផ្តល់លទ្ធភាពទទួលបាន និងការតភ្ជាប់ ការចែករំលែកព័ត៌មានស៊ីជម្រៅដើម្បីជួយអាជីវកម្មឱ្យដំណើរការតាមគន្លងប្រក្រតីភាពថ្មី។ កត្តានេះបានបង្កើតទាំងឱកាស និងឧបសគ្គ ក៏ដូចជាជួយយើងឱ្យសម្រេចចិត្តថា តើគួរផ្សារភ្ជាប់ទំនាក់ទំនងជាមួយ MSME ដោយរបៀបណា។ ជាងពាក់កណ្តាល (៧៣%) នៃសហគ្រាស MSME ដែលមានសកម្មភាពអាជីវកម្មអនឡាញដែលយល់ដឹងពីមុខងារឌីជីថល មានសារៈសំខាន់ក្នុងដំណើរការអាជីវកម្ម។ យើងត្រូវជួយពួកគេឱ្យស្វែងរកលទ្ធភាពបន្ថែមទៀតអំពីពាណិជ្ជកម្មលើបណ្តាញសង្គម និងផ្តល់ការអប់រំអំពីវិធីសាស្ត្រប្រសើរបំផុតក្នុងការប្រើប្រាស់មុខងារឌីជីថល ដើម្បីធ្វើឱ្យអាជីវកម្មរបស់ពួកគេមានភាពប្រសើរឡើង»។

សហគ្រិនមួយរូបបានថ្លែងថា៖ «បណ្តាញទំនាក់ទំនងសង្គម ជាពិសេស Facebook បានដើរតួនាទីយ៉ាងសំខាន់សម្រាប់អាជីវកម្មក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩។ អំឡុងពេលពិបាកបំផុតក្នុងវិបត្តិនេះ យើងបានប្រែក្លាយអាជីវកម្មទាំងអស់របស់យើងទៅជាអន

ឡាញ ហើយសូម្បីតែពេលនេះ ជាពេលដែលអត្រាឆ្លងជំងឺកូវីដ-១៩ បានធ្លាក់ចុះទៅហើយក្តី ក៏យើងនៅតែបន្តប្រើប្រាស់Facebook និងមុខងារឌីជីថលផ្សេងៗទៀតធ្វើជាមធ្យោបាយចម្បង ដើម្បីទាក់ទងនិងផ្សារភ្ជាប់ជាមួយអតិថិជនរបស់យើងផងដែរ»។

អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា៖ «ឌីជីថលូបនីយកម្មសហគ្រាស គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភចម្បងចំនួន ៣ ដែលដាក់ចេញនៅក្នុង "ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥។ ក្នុងន័យនេះ ក្រសួងដែលមានតួនាទីនាំមុខគេក្នុងការសម្របសម្រួលការងារនេះ បាននិងកំពុងប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជួយដល់ក្រុមហ៊ុនអាជីវកម្មដើម្បីឱ្យពួកគេមានលទ្ធភាពសម្របខ្លួនទៅនឹងបច្ចេកវិទ្យាឌីជីថល និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះដើម្បីលើកកម្ពស់ប្រតិបត្តិការ និងពង្រីកទីផ្សាររបស់ខ្លួន។ ឌីជីថលូបនីយកម្មរបស់ក្រុមហ៊ុនអាជីវកម្មគឺជាគន្លឹះសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងកសាងភាពធន់របស់ប្រទេសយើងនៅក្រោយពេលការរាតត្បាតជំងឺ។ ក្រសួងនឹងបន្តធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន Meta និងកម្មវិធីរបស់ក្រុមហ៊ុននេះ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់បេសកកម្មដ៏សំខាន់នេះ ដើម្បីសម្រេចបានពេញលេញនូវការផ្លាស់ប្តូរទៅជាឌីជីថលរបស់កម្ពុជានៅឆ្នាំខាងមុខ»៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១។*

## រោងចក្រផលិតសម្បកកង់ធំមួយរបស់ចិន គ្រោងបោះទុនវិនិយោគ ៣០០លានដុល្លារ សង់រោងចក្រនៅខេត្តព្រះសីហនុ




*ដោយ ខាមបូណ្ឌមីស*

គម្រោងវិនិយោគរោងចក្រផលិតសម្បកកង់រថយន្តដ៏ធំមួយរបស់ចិន Celimo Tires ថ្មីនេះ បានសម្រេចបោះទុនវិនិយោគសរុប ៣០០លានដុល្លារអាមេរិក នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដោយគម្រោងនេះ នឹងត្រូវវិនិយោគដោយក្រុមហ៊ុន Hondo Group ដែលជាសហគ្រាសឯកជនមួយនៅក្នុងខេត្តជាំងស៊ូ ប្រទេសចិន ហើយគម្រោងនេះ ក៏ជាគម្រោងឧស្សាហកម្មធំជាងគេបំផុតមួយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុផងដែរ។

តំណាងក្រុមហ៊ុន Hondo Groupបានអះអាងថា រោងចក្រនេះ នឹងមានប្រតិបត្តិការនៅមុនចុងឆ្នាំ២០២២ខាងមុខ ដោយវាមានសមត្ថភាពផលិតសម្បកកង់រថយន្តបានដល់ទៅ៦លានសម្បកកង់ក្នុងមួយឆ្នាំ។ សម្បកកង់រថយន្ត ដែលផលិតបាន នឹងត្រូវបានលក់ទៅទីផ្សាររដ្ឋអាមេរិក និងប្រេស៊ីលជាដើម។

អភិបាលរងខេត្តព្រះសីហនុបានលើកឡើងថា តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានទាក់ទាញសហគ្រាស និងស្ថាប័នឯកជនចំនួន ១៧០ក្រុមហ៊ុនមកពីប្រទេសចិន អឺរ៉ុប សហរដ្ឋអាមេរិច អាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងទៀត។ បើគិតចាប់ពីខែមករា ដល់ខែវិច្ឆិកាឆ្នាំ២០២១ ទំហំពាណិជ្ជកម្មនៃសហគ្រាសតំបន់នេះកើន

ឡើងជាង ៤០%ធៀបរយៈពេលដូចគ្នានៃឆ្នាំកន្លងទៅ។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដើរតួនាទីជាអ្នកបើកច្រកពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការទូលំទូលាយផ្នែកពាណិជ្ជកម្មអន្តរជាតិក្នុងតំបន់ និងពិភពលោកផងដែរ។

បច្ចុប្បន្នខេត្តព្រះសីហនុមានតំបន់សេដ្ឋកិច្ចពិសេសចំនួន ១១ បានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានសម្ពោធដាក់ដំណើរការតាំងពីឆ្នាំ២០០៨មកម្ល៉េះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ខាមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។*

## អ្នកជំនាញស្នើឱ្យពន្យារពេលអនុវត្តយកពន្ធចំណេញលើមូលធនបន្តទៀត




*ដោយ ខេមបូណ្ឌមីស*

អគ្គនាយកដ្ឋានពន្ធដារ នឹងចាប់ផ្តើមអនុវត្តយកពន្ធលើប្រាក់ចំណេញមូលធនចាប់ពីឆ្នាំ២០២២តទៅ ក្រោយពីបានពន្យារពេលអនុវត្តអស់រយៈពេល១ឆ្នាំកន្លងមកនេះ។ ការយកពន្ធលើប្រាក់ចំណេញមូលធននេះត្រូវបានគេអនុវត្តនៅតាមប្រទេសក្នុងតំបន់អាស៊ាន អាស៊ី និងពិភពលោករួចមកហើយ។

អ្នកវិនិយោគជាតិ និងអន្តរជាតិមិនសូវសប្បាយចិត្តទេ ប្រសិនរាជរដ្ឋាភិបាលចាប់អនុវត្តនាឆ្នាំក្រោយមែននោះ។ ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជាយល់ឃើញថា រាជរដ្ឋាភិបាលមិនគួរអនុវត្តការយកពន្ធនេះភ្លាមៗនោះទេ ដ្បិតវាហាក់លឿនពេក សម្រាប់វិស័យអចលនទ្រព្យកម្ពុជា ដែលបានរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិកូវីដ-១៩ពីរឆ្នាំកន្លងមកនេះ។ ដូច្នេះគួរពន្យារពេលអនុវត្ត២ទៅ៣ឆ្នាំទៀត ទុកពេលឱ្យប្រជាពលរដ្ឋ និងអ្នកវិនិយោគមានលទ្ធភាពក្នុងការស្តារវិស័យអចលនទ្រព្យឱ្យមានភាពល្អប្រសើរឡើងវិញសិន។

ជុំវិញបញ្ហានេះ អគ្គនាយកក្រុមហ៊ុនអចនទ្រព្យ CPL ជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ការសម្រេចចិត្តមួយដ៏ស័ក្តិសមក្នុងការអនុវត្តការប្រមូលពន្ធលើប្រាក់ចំណេញមូលធននេះ។ ទន្ទឹមនឹងនេះ អ្នកជំនាញមានបទពិសោធន៍ជាង២០ឆ្នាំក្នុងវិស័យអចលនទ្រព្យរូបនេះ បានបង្ហាញការគាំទ្រចំពោះយន្តការប្រមូលពន្ធនេះ ដ្បិតថា វាជាការជួយអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនប្រាក់ចំណូលរដ្ឋ។

អគ្គនាយកដ្ឋានពន្ធដារនាពេលកន្លងមកបានឱ្យដឹងថា ពន្ធលើចំណេញមូលធននេះ គឺមានអនុវត្តលើការលក់អចលនវត្ថុ ដោយអចលនវត្ថុដែលលក់បាន ត្រូវដកយក២០%នៃតម្លៃលក់នោះ មកគិតពន្ធ ២០%។ ជាឧទាហរណ៍ បើអ្នកលក់ផ្ទះ១ខ្នងបានក្នុងតម្លៃ ១លានដុល្លារ នោះ នឹងត្រូវយកតម្លៃ ២០% នៃតម្លៃផ្ទះនោះមកគិតពន្ធ ២០% ដែលបានកំណត់។ ដូច្នេះ បើអ្នកលក់ផ្ទះនោះ បានក្នុងតម្លៃ១លានដុល្លារ នោះអ្នកនឹងត្រូវបង់ពន្ធចំណេញមូលធននេះ ៤ម៉ឺនដុល្លារ។ ការយកពន្ធប្រភេទនេះ ក៏នឹងលើកលែងដែរ ចំពោះការលក់ ឬផ្ទេរទ្រព្យប្រភេទទ្រព្យដែលជាកម្មសិទ្ធិស្ថាប័នរដ្ឋ ទ្រព្យកម្មសិទ្ធិបេសកកម្មការទូតបរទេស ឬកុងស៊ុលបរទេស និងអង្គការអន្តរជាតិ ឬទីភ្នាក់ងារប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃ។ ចំពោះការផ្ទេរអចលនទ្រព្យរវាងសាច់ញាតិដែលមានការលើកលែងនៅក្នុងពន្ធប្រថាប់ត្រា នោះក៏នឹងទទួលបានការលើក

លែងលើពន្ធលើចំណេញមូលធននេះផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។*

## សេចក្តីព្រាងច្បាប់ពាណិជ្ជកម្មសំខាន់ៗចំនួន៣ នឹងជួយស្តារសេដ្ឋកិច្ច និងសង្គមកម្ពុជាពីវិបត្តិកូវីដ១៩




*ដោយ ខេមបូឌាមីស*

សេចក្តីព្រាងច្បាប់សំខាន់ៗចំនួន៣ របស់ក្រសួងពាណិជ្ជកម្ម ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តរួចហើយ រួមមាន សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម សេចក្តីព្រាងស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និង សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។ ចំពោះការធ្វើវិសោធនកម្ម ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម វិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម មានគោលបំណងជួយឱ្យប្រព័ន្ធស្វ័យប្រវត្តិកម្មដំណើរការទៅបានរលូននិងមានតម្លាភាពមានស្តង់ដារខ្ពស់ស្របតាមការធ្វើធុរកិច្ចជាសកល។ ដោយឡែក សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងកូរ៉េខាងត្បូងវិញ នឹងក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញលំហូរពាណិជ្ជកម្ម និងការវិនិយោគរវាងភាគីទាំងពីរ ផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកផ្នែកសេដ្ឋកិច្ច ការអភិវឌ្ឍ សុខមាលភាពប្រជាជន និងការផ្សារភ្ជាប់ធុរកិច្ចនៃប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជាបានអះអាងថា សេចក្តីព្រាងច្បាប់ទាំងបីនេះ នឹងជួយធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងសង្គតិភាព ក្នុងក្របខណ្ឌគតិយុត្តរបស់កម្ពុជា ព្រមទាំងលើកស្ទួយបរិយាកាសធុរកិច្ចនៅកម្ពុជា សំដៅចូលរួមស្តារសង្គម-សេដ្ឋកិច្ចកម្ពុជាពីវិបត្តិកូវីដ១៩ ផ្តល់នូវប្រយោជន៍ជាសារវ័ន្តដល់សង្គមជាតិទាំងមូលផងដែរ។ កម្ពុជាក៏នឹងទទួលបានអត្ថប្រយោជន៍បន្ថែមពីកិច្ចព្រមព្រៀងនេះមានជាអាទិ៍ ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ និងជំនាញថ្មីៗពីការវិនិយោគផ្ទាល់របស់បរទេស ព្រមទាំងបង្កើតការងារថ្មីៗជូនប្រជាជនកម្ពុជា ផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ការប្រៀបធៀបការនាំចេញមុខទំនិញផ្សេងៗ ក្នុងរយៈពេល១០ខែ ឆ្នាំ២០២១

ស្ថិតិនាំចេញមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | មុខទំនិញផ្សេងទៀត | រយពេល ១០ខែឆ្នាំ ២០២០ | រយៈពេល ១០ខែ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 14550 | 14288 | -2% |
| 1 | សម្លៀកបំពាក់ | 6099 | 6538 | 7% |
| 2 | ស្បែកជើង | 922 | 1114 | 21% |
| 3 | សម្ភារៈធ្វើដំណើរ | 775 | 1179 | 52% |
| 4 | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | 601 | 850 | 41% |
| 5 | កង់ | 426 | 514 | 21% |
| 6 | អង្ករ | 365 | 326 | -11% |
| 7 | គ្រឿងសង្ហារឹម និង បរិធានបំភ្លឺ | 555 | 776 | 40% |
| 8 | កៅស៊ូក្រែប | 195 | 329 | 69% |
| 9 | ស្ករអំពៅ | 32 | 42 | 31% |
| 10 | បន្លែនិងផ្លែឈើ | 110 | 167 | 52% |
| 11 | មុខទំនិញផ្សេងទៀត | 4470 | 2453 | -45% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២១*

តារាងទី១៖ តារាងខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបការនាំចេញមុខទំនិញផ្សេងៗ ក្នុងរយៈពេល១០ខែដើមឆ្នាំ២០២១ ដែលមានកំណើនថយ ២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ទំនិញនាំចេញទាំងនេះរួមមាន ៖ សម្លៀកបំពាក់ ស្បែកជើង សម្ភារៈធ្វើដំណើរ ម៉ាស៊ីនបរិធាននិងសម្ភារៈអគ្គិសនី អង្ករ កង់ គ្រឿងសង្ហារឹមនិងបរិធានបំភ្លឺ កៅស៊ូក្រែប ស្ករអំពៅ បន្លែនិងផ្លែឈើ និងមុខទំនិញផ្សេងទៀត។ នេះបើយោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

ការនាំចេញទំនិញក្នុងរយៈពេល១០ខែ ឆ្នាំ២០២១នេះ មានការកើនឡើងខ្លាំងលើកៅស៊ូក្រែប បន្លែនិងផ្លែឈើ និងសម្ភារៈធ្វើដំណើរ។ កៅស៊ូក្រែប មានការកើនឡើងយ៉ាងខ្លាំងដល់៦៩% បន្ទាប់មកសម្ភារៈធ្វើដំណើរ និងបន្លែនិងផ្លែឈើកើន ៥២% ដូចគ្នា។ ម៉ាស៊ីនបរិធាននិងសម្ភារៈអគ្គិសនី គ្រឿងសង្ហារឹមនិងបរិធានបំភ្លឺ ស្ករអំពៅ (កង់ និងស្បែកជើងស្មើគ្នា) និងសម្លៀកបំពាក់បានកើន ៤១%, ៤០%, ៣១%, ២១%, ៧% រៀងគ្នា បើធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ រីឯការនាំចេញមុខទំនិញផ្សេងៗទៀតបានថយចុះខ្លាំងចំនួន ៤៥% និងអង្ករថយចុះចំនួន១១% បើធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ *ដោយ ឈន ហាំ*

### តារាងទី២៖ ការប្រៀបធៀបការនាំចូលមុខទំនិញផ្សេងៗ ក្នុងពេល១០ខែ ឆ្នាំ២០២១

ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | មុខទំនិញផ្សេងទៀត | រយៈពេល ១០ខែឆ្នាំ ២០២០ | រយៈពេល ១០ខែ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 14624 | 23060 | 58% |
| 1 | វាយនភ័ណ្ឌ | 3533 | 4412 | 25% |
| 2 | សម្ភារៈសំណង់ | 802 | 1063 | 33% |
| 3 | ដែក | 321 | 326 | 2% |
| 4 | ស៊ីម៉ង់ត៍ | 59 | 40 | -32% |
| 5 | ទឹកបរិសុទ្ធ | 260 | 225 | -13% |
| 6 | ស្រាបៀរ និងស្រាចំរុះ | 14 | 8 | -43% |
| 7 | រថយន្ត | 901 | 977 | 8% |
| 8 | ផលិតផលឱសថ | 319 | 614 | 92% |
| 9 | ជីកសិកម្ម និងថ្នាំ | 276 | 390 | 41% |
| 10 | គ្រឿងអេឡិច និង សម្ភារៈអគ្គិសនី | 1907 | 2014 | 6% |
| 11 | មុខទំនិញផ្សេងទៀត | 6232 | 12991 | 108% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២១*

តារាងទី២៖ តារាងខាងលើនេះបានបង្ហាញថា ពីការប្រៀបធៀបការនាំចូលមុខទំនិញផ្សេងៗ ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២១ មានកំណើន៥៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ទំនិញនាំចូលទាំងនេះ រួម

មាន ៖ វាយនភ័ណ្ឌ សម្ភារៈសំណង់ ដែក ស៊ីម៉ង់ត៍ ទឹកបរិសុទ្ធ ស្រាបៀរនិងស្រាចំរុះ រថយន្ត ផលិតផលឱសថ ជីកសិកម្មនិងថ្នាំ គ្រឿងអេឡិចនិងសម្ភារៈអគ្គិសនី និងមុខទំនិញផ្សេងទៀត។ បើយោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

ក្នុងរយៈពេល១០ខែដើមឆ្នាំ២០២១នេះ ការនាំចូលមុខទំនិញផ្សេងទៀត មានកំណើនខ្លាំងគួរឱ្យកត់សម្គាល់ ដែល មានចំនួន ១០៨% និងបន្ទាប់មកផលិតផលឱសថកើន ៩២% ។ ជីកសិកម្មនិងថ្នាំ សម្ភារៈសំណង់ វាយនភ័ណ រថយន្ត គ្រឿងអេឡិចនិងសម្ភារៈអគ្គិសនី និងដែកកើន ៤១%, ៣៣%, ២៥%, ៨%, ៦%, ២% រាងគ្នា បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ រីឯការនាំចូល ស្រាបៀរនិងស្រាចំរុះ ស៊ីម៉ង់ត៍ និងទឹកបរិសុទ្ធ បានថយចុះ ៤៣%, ៣២%,១៣% រាងគ្នា បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ *ដោយ ឈន ហាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ឥណ្ឌូណេស៊ីនឹងលក់មូលបត្របំណុលជិត ១១ ប៊ីលានដុល្លារទៅឱ្យធនាគារកណ្តាលនៅចុងឆ្នាំ




*ប្រភព៖ CNA,2021*

រដ្ឋាភិបាលឥណ្ឌូនេស៊ី នឹងលក់មូលបត្របំណុលចំនួន ១៥៧ ទ្រីលានរូព្យ៉ា (១០,៩៤ ប៊ីលានដុល្លារអាមេរិក) ទៅកាន់ធនាគារកណ្តាលមុនដំណាច់ឆ្នាំ ២០២១ ដើម្បីប្រើប្រាស់កិច្ចព្រមព្រៀងហិរញ្ញប្បទានឱនភាពសារពើពន្ធ ដែលបានព្រមព្រៀងគ្នាក្នុងខែសីហា នេះបើយោងតាមការបង្ហាញរបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុ។
រដ្ឋាភិបាល បានលក់មូលបត្របំណុលចំនួន ៥៨ ទ្រីលានរូព្យ៉ា ទៅឱ្យធានាគាឥណ្ឌូនេស៊ី (BI) រួចហើយកាលពីដើមខែនេះ។ ហើយក្រោមកិច្ចព្រមព្រៀងខែសីហា BI ផ្តល់ជូនការទិញមូលបត្របំណុលក្រោមតម្លៃទីផ្សារដែលមានទំហំទឹកប្រាក់ ២១៥ទ្រីលានរូពៀក្នុងឆ្នាំ២០២១ និង ២២៤ទ្រីលានរូព្យ៉ា ក្នុងឆ្នាំ២០២០ ដើម្បីជួយរដ្ឋាភិបាលក្នុងការគ្រប់គ្រងការទូទាត់ការប្រាក់ចំពេលមានការកើនឡើងបំណុលក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ Sri Mulyani Indrawati បានលើកឡើងថា ការយកពន្ធប្រចាំឆ្នាំមានភាពរឹងមាំដោយសារតែការកើនឡើងនៃតម្លៃទំនិញ។ លើសពីនេះ កិច្ចព្រមព្រៀងជាមួយ BI និងការប្រើប្រាស់ទុនបម្រុងសាច់ប្រាក់របស់រដ្ឋាភិបាល មានន័យថាអាជ្ញាធរអាចកាត់បន្ថយគោលដៅនៃការចេញមូលបត្របំណុលដោយ ២៥៣.៥ ទ្រីលានរូព្យ៉ា នៅឆ្នាំនេះ។

ទន្ទឹមនឹងនេះ ប្រាក់ចំណូលសរុបនៅក្នុងឆ្នាំដល់ខែវិច្ឆិកាគឺ ១៩.៤% ខ្ពស់ជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែលមានចំនួន ១ ៦៩៩.៤ ទ្រីលានរូព្យ៉ា ហើយគោលដៅប្រាក់ចំណូលទំនងជានឹងមានអតិរេក។ ការចំណាយសរុបក្នុងឆ្នាំនេះគិតត្រឹមខែវិច្ឆិកាគឺ ២ ៣១០.៤ ទ្រីលានរូព្យ៉ា ខណៈដែលឱនភាពសារពើពន្ធមានចំនួន ៦១១ ទ្រីលានរូព្យ៉ា ក្នុងខែវិច្ឆិកា ឬ ៣.៦៣% នៃផ.ស.ស ធៀបនឹងការព្យាករណ៍ឱនភាពថវិកាចុងក្រោយបំផុតក្នុងឆ្នាំ

២០២១ ក្នុងចន្លោះពី ៥.១% ទៅ ៥.៤%នៃផ.ស.ស។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNA ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១*

## វៀតណាមព្យាយាមចាប់យកឱកាសសម្រាប់សេដ្ឋកិច្ចឌីជីថល



*ប្រភព៖ VEN.vn,2021*

វៀតណាម មានគុណសម្បត្តិជាច្រើនទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថល ដែលផ្តើមចេញពីផលប៉ះពាល់នៃបដិវត្តន៍ឧស្សាហកម្មទី៤ យន្តការ និងគោលនយោបាយរបស់រដ្ឋ និងតម្រូវការសេដ្ឋកិច្ចដែលមិនអាចជៀសបានក្នុងបរិបទនៃការរាតត្បាតកូវីដ១៩ ដែលជះឥទ្ធិពលដល់ការរស់នៅរបស់បុគ្គល និងអាជីវកម្ម។

មហាសន្និបាតបក្សជាតិលើកទី១៣ បានអនុម័តសេចក្តីសម្រេចចិត្តកំណត់សេដ្ឋកិច្ចឌីជីថល ជាលក្ខណៈវិនិច្ឆ័យសំខាន់មួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដែលទាមទារឱ្យសេដ្ឋកិច្ចឌីជីថល មាន២៥%នៃផ.ស.ស នៅឆ្នាំ២០២៥ និង ៣០% នៃផ.ស.ស នៅឆ្នាំ២០៣០។

រដ្ឋាភិបាលវៀតណាមក៏បានចេញនូវគោលនយោបាយជាច្រើនដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល(បណ្តាញទូរគមនាគមន៍ និងសេវាឌីជីថល) និងកសាងធនធានឌីជីថល (ចំណេះដឹងបើកចំហ និងប្រព័ន្ធអេកូទិន្នន័យ) ក៏ដូចជាគោលនយោបាយផ្លាស់ប្តូរឌីជីថលផងដែរ។

ហើយប្រាក់ចំណូលនៃវិស័យបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) មានអត្រាកំណើនខ្ពស់ ៧,១% ក្នុងមួយឆ្នាំ ដែលបង្កើតគុណសម្បត្តិសម្រាប់ធុរកិច្ចវៀតណាមក្នុងការចូលរួមក្នុងទីផ្សារផ្លាស់ប្តូរឌីជីថល ឬ សេវាកម្មឌីជីថល។

ទន្ទឹមនឹងនេះ វៀតណាម ខ្វះខាតនៅកម្លាំងពលកម្មក្នុងវិស័យនេះ ដែលតម្រូវការនៃបុគ្គលិកផ្នែកបច្ចេកវិទ្យាព័ត៌មាន (IT) គឺមានចំនួន ៤៥០ ០០០នាក់ក្នុងឆ្នាំ ២០២១ ខណៈពេលដែលមានត្រឹមតែ ៤៣០ ០០០នាក់ ហើយមនុស្សប្រហែល ១៦ ៥០០ នាក់ បានបញ្ចប់ការសិក្សាជារៀងរាល់ឆ្នាំ។ ជាមួយគ្នានេះ កង្វះធនធានមនុស្សដែលមានជំនាញឌីជីថលត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ១៥០ ០០០នាក់នៅឆ្នាំ ២០២២ ។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន VEN.vn ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១*

## ពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសថៃ សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារអាមេរិក)

ការនាំចេញរបស់ប្រទេសថៃកើនដល់ ២៣,៦៥ ពាន់លានដុល្លារអាមេរិក ជាមួយនឹងអត្រាកំណើន ២៤,៧% ខណៈដែលការនាំចេញ នៃវិស័យជាក់ស្តែង (real sector) មិនរាប់បញ្ចូល មាស ផលិតផលទាក់ទងនឹងប្រេង (oil-related product) និងអាវុធ បានបន្តកើនឡើង ១៨,៩% ។ ផលិតផលដែលបានជំរុញកំណើនយ៉ាងខ្លាំងក្នុងខែវិច្ឆិកា ឆ្នាំ២០២១ មានដូចជា ផលិតផលកសិកម្ម និងម្ហូបអាហារ; ផលិតផលធ្វើការពីផ្ទះ និងគ្រឿងប្រើប្រាស់ក្នុងផ្ទះ (Work from home product and home appliances); ផលិតផលការការពារជំងឺកូវីដ-១៩ និងផលិតផលវេជ្ជសាស្ត្រ; ទំនិញអន្តរការី (intermediate goods) និងវត្ថុធាតុ និងទំនិញប្រើប្រាស់ជាប់បានយូរ ឬទំនិញប្រណិត(Durable goods or luxury goods)។

សរុបមក ការនាំចេញរបស់ថៃក្នុងខែវិច្ឆិកា ឆ្នាំ២០២១ បានកើនឡើង២៤,៧% ខណៈពេលដែលការនាំចូល

បានកើនឡើង ២០,៥% ដែលនាំឱ្យប្រទេសថៃមានអតិរេកពាណិជ្ជកម្ម ១,០២ ពាន់លានដុល្លារ។ *ដោយ ជីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២៣,៦៥ |
| ការនាំចេញ | ២២,៦៣ |
| តុល្យភាពពាណិជ្ជកម្ម | ១,០២ |

*ប្រភព៖ tpso.moc.go.th*

## ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេងរបស់សិង្ហបុរីទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែតុលា ឆ្នាំ២០២១

តារាងខាងក្រោមបង្ហាញពី ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX: (Non-oil domestic exports)) ទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែតុលា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

NODX ទៅកាន់ចិនបានកើនឡើង ៣៥,៦% នៅក្នុងខែតុលា ឆ្នាំ២០២១ ខណៈ NODX កាលពីខែមុនកើន ៣៨,៨%។ កំណើននេះជំរុញដោយមិនមែនរូបិយវត្ថុមាស (non-monetary gold) ម៉ាស៊ីនឯកទេសមាន៥៣,១% និងគីមីឥន្ទនៈ (petrochemicals) មាន២១,៦%។

NODXទៅកាន់ម៉ាឡេស៊ីបានកើនឡើង ២៩,៤% នៅក្នុងខែតុលា ឆ្នាំ២០២១ បន្ទាប់ពីមានការធ្លាក់ចុះ ៤,១% កាលពីខែកញ្ញា ឆ្នាំ២០២១។ កំណើននេះរួមចំណែកដោយ Import Certificate (ICs) មាន ៤៧,៣% មិនមែនរូបិយវត្ថុមាសមាន ២៣៤,៤% និង diodes និងត្រង់ស៊ីស្ទ័រ (transistors) មាន ៤៧,២%។

NODX ទៅកាន់កោះតៃវ៉ាន់បានកើនឡើង ៣២,៧% នៅក្នុងខែតុលា ឆ្នាំ២០២១ បន្ទាប់ពីមានកំណើន៣០,៣% កាលពីខែមុន។ ការកើនឡើងនេះ ដោយសារការនាំចេញសារ Import Certificate (ICs) មាន ៤១% ម៉ាស៊ីនឯកទេសមាន២១,៦% និងគីមីឥន្ទនៈ (petro-chemicals) មាន ១៤៤,៤%។

ជារួម NODX ទៅកាន់ទីផ្សារធំៗទាំង១០ បានកើនឡើងនៅក្នុងខែតុលា ឆ្នាំ២០២១ ទោះបីជា NODX ទៅទីផ្សារហុងកុង និងថៃបានធ្លាក់ចុះក៏ដោយ។ ទីផ្សារធំបំផុតនៃNODX របស់សង្ហបុរី គឺចិនមាន ៣៥,៦% ម៉ាឡេស៊ីមាន ២៩,៤% និងតៃវ៉ាន់មាន៣២,៧%។ *ដោយ ជីម ប៊ុនធឿន*

| ទីផ្សារធំៗ | កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (%) | |
|---|---|---|
| | កញ្ញា ឆ្នាំ ២០២១ | តុលា ឆ្នាំ ២០២១ |
| ចិន | 38.9 | 35.6 |
| ម៉ាឡេស៊ី | -4.1 | 29.4 |
| តៃវ៉ាន់ | 30.3 | 32.7 |
| កូរ៉េខាងត្បូង | 61.6 | 56.6 |
| សហគមន៍អឺរ៉ុប | -37.9 | 13.1 |
| ឥណ្ឌូនេស៊ី | 21.9 | 22.3 |
| ជប៉ុន | 25.1 | 4.5 |
| ហុងកុង | 18.5 | -0.2 |
| អាមេរិក | 21.9 | -3.9 |
| ថៃ | -7.5 | -12.6 |

*ប្រភព៖www.enterprisesg.gov.sg*

## កម្ពុជារំពឹងទទួលបានហិរញ្ញប្បទានឥតសំណងពីអាមេរិក ៣០០លានដុល្លារ នៅត្រីមាសទី១ឆ្នាំ២០២២



*ដោយ ខេមបូណ្ណមីស*

នៅក្រោយជំនួបពិភាក្សាការងារ រវាងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២១ បានឱ្យដឹងថា អាមេរិក នឹងផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ៣០០លានដុល្លារអាមេរិក សម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ដល់២០២៥។ កម្ពុជា និងអាមេរិក ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ហិរញ្ញប្បទានសហប្រតិបត្តិការរវាងរដ្ឋាភិបាលប្រទេសទាំងពីរ នៅអំឡុងត្រីមាសទី១ឆ្នាំ២០២២ខាងមុខនេះ។ ហិរញ្ញប្បទានឥតសំណងនេះ សហរដ្ឋអាមេរិកផ្តល់ឱ្យកម្ពុជា សម្រាប់គាំទ្រដល់វិស័យសំខាន់ៗដូចជា សុខាភិបាល អប់រំ កសិកម្ម និងបរិស្ថាន សម្រាប់រយៈពេល៥ឆ្នាំ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា តាមរយៈទីភ្នាក់ងារUSAID អាមេរិកបានផ្តល់ជំនួយជាច្រើនដល់កម្ពុជា ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់វិស័យសុខាភិបាល អប់រំ កសិកម្ម បរិស្ថាន និងអភិបាលកិច្ច និងអន្តរវិស័យ។ ជាពិសេស សហរដ្ឋអាមេរិកបានផ្តល់នូវហិរញ្ញប្បទាន ឥតសំណងប្រមាណ ១៥ លានដុល្លារអាមេរិក និងវ៉ាក់សាំងកូវីដ១៩ (Johnson & Johnson) ចំនួនប្រមាណជាង ១ លានដូស ដល់កម្ពុជាគាំទ្រដល់វិធានការឆ្លើយតបនឹងជំងឺកូវីដ-១៩ និងវិធានការស្តារសេដ្ឋកិច្ច និងសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជានៅអំឡុងពេលនៃវិបត្តិកូវីដ១៩ នេះផងដែរ។

ជាមួយគ្នានេះដែរ ឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិកបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសការគ្រប់គ្រងបានល្អនៃការឆ្លងរីករាលដាលកូវីដ១៩ និងការសម្រេចបានចាក់វ៉ាក់សាំងជូនដល់ប្រជាជនកម្ពុជា និងជនប្រទេសរស់នៅ និងធ្វើការនៅកម្ពុជាផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។*

## កម្ពុជា-ចិន បំបែកកំណត់ត្រាគោលដៅទំហំពាណិជ្ជកម្ម ១០ពាន់លានដុល្លារ មុនផែនការកំណត់



*ដោយ ខេមបូណ្ណមីស(រូបតំណាង៖ ពាណិជ្ជកម្មកម្ពុជា)*

នៅរយៈពេល ១០ខែដំបូង ក្នុងឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាង កម្ពុជា-ចិន បានកើនដល់ទៅជិត១១ពាន់លានដុល្លារអាមេរិក(កើនជិត៥០%) បើប្រៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ គឺជាកំណើនលើសពីផែនការដែលប្រទេសទាំងពីរបានគ្រោងទុកនៅឆ្នាំ២០២៣។ តើមានកត្តាជំរុញពីក្រោយអ្វីខ្លះ ដែលធ្វើឱ្យទំហំពាណិជ្ជកម្មរវាងកម្ពុជា និងចិនកើនខ្ពស់ និងលើសផែនការកំណត់យ៉ាងដូច្នេះ?

រយៈពេលចុងក្រោយនេះភាគីទាំងពីរសុទ្ធតែបានពង្រីកទំហំនៃការនាំទំនិញចេញ-ចូលរៀងៗខ្លួន។ ចិន កាន់តែ

មានទំទុកចិត្ត លើគុណភាពលើទំនិញកម្ពុជា ទើបធ្វើឱ្យទំហំពាណិជ្ជកម្មកម្ពុជា-ចិន លើសពីអ្វីដែលប្រទេសទាំងពីរបានគ្រោងទុក។

ទំនិញដែលកម្ពុជានាំចេញទៅចិន ភាគច្រើនជាកសិផល ហើយនាំផលិតផលពីចិនមកកម្ពុជា ភាគច្រើនជាវត្ថុធាតុដើមដូចជា ផ្នែកវាយនភ័ណ្ឌ និងឧស្សាហកម្ម។ មិនមែនតែកសិផលនោះទេដែលកម្ពុជា បាននាំចេញទៅប្រទេសចិន ក្នុងនោះ ក៏មានដូចជា ផលិតផលសម្លៀកបំពាក់ និងស្បែកជើងផងដែរ។ ក្តីរំពឹងខ្ពស់មានបន្ថែមទៀតផងដែរថា កម្ពុជា-ចិន ក្រោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ចូលជាធរមាននៅដើមឆ្នាំ២០២២ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ នឹងកាន់តែកើនខ្ពស់បន្ថែមទៀត។ បច្ចុប្បន្ន វិនិយោគិនចិនក៏ស្ថិតនៅក្នុងកំពូលតារាងវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជាផងដែរ ពិសេសនៅក្នុងការវិនិយោគលើវិស័យអចលនទ្រព្យ និងសំណង់តែម្តង។

សព្វថ្ងៃ ផលិតផលកម្ពុជា ពិសេសកសិផលដូចជា អង្ករ ផ្លែស្វាយស្រស់ ផ្លែចេកស្រស់ និងកសិផលដទៃផ្សេងទៀត កាន់តែបង្ហាញពីវិសាលភាពនៅលើទីផ្សារអន្តរជាតិ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### អ្នកសេដ្ឋកិច្ចបានកាត់បន្ថយការព្យាករណ៍កំណើនសេដ្ឋកិច្ច របស់សហរដ្ឋអាមេរិកសម្រាប់ឆ្នាំ២០២២ ដោយសារការរាំងស្ទះនៃផែនការចំណាយរបស់រដ្ឋបាលប្រធានាធិបតី ចូ បៃដិន




*ប្រភព៖ reuters, 2021 រូបភាព៖ Elizabeth Frantz*

បន្ទាប់ពី សមាជិកសភាប្រជាធិបតេយ្យដ៏សំខាន់ម្នាក់បានបញ្ជាក់ពីការប៉ះទង្គិចនៃផែនការចំណាយរបស់ រដ្ឋបាលនៃសហរដ្ឋអាមេរិកដែលមានចំនួន១,៧៥ទ្រីលានដុល្លារ បានធ្វើឱ្យទស្សនៈវិស័យមួយចំនួនជួបនូវបញ្ហាប្រឈមខ្ពស់ស្របពេលដែលមានការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដបម្លែងថ្មី អូមីក្រុង (Omicron) ជាហេតុនាំឱ្យ អ្នកសេដ្ឋកិច្ចមួយចំនួនរំពឹងថាសេដ្ឋកិច្ចសហរដ្ឋអាមេរិកនឹងកើនឡើងយឺតៗនៅឆ្នាំក្រោយ។

កត្តាមួយដែលធ្វើឱ្យអ្នកសេដ្ឋកិច្ចធ្វើការកាត់បន្ថយកំណើនសេដ្ឋកិច្ចគឺការផ្លាស់ប្តូរការកាត់បន្ថយឥណទានពន្ធដែលកន្លងមកជាទូទៅគ្រួសារបង់ប្រាក់ប្រចាំខែរហូតដល់ ៣០០ ដុល្លារសម្រាប់កូនម្នាក់ប៉ុន្តែត្រូវបានផុតកំណត់នៅថ្ងៃទី ៣១ ខែធ្នូ។ សមាជិកសភាអាចអនុម័តកំណែដែលបានកែប្រែផែនការចំណាយរបស់រដ្ឋ នៅឆ្នាំក្រោយ ឬសម្រេចចិត្តពន្យារពេល

តណទានឡើងវិញទោះបីជាការចរាចរអាចចំណាយពេលច្រើនសប្តាហ៍ក៏ដោយ។

អ្នកសេដ្ឋវិទូបានព្យាករនៅដើមខែនេះថា កំណើននឹងថយចុះនៅឆ្នាំក្រោយ ដោយសារការកើនឡើងដែលផ្តល់ដោយកម្មវិធីចំណាយពីមុនបានធ្លាក់ចុះ ហើយធនាគារកណ្តាលបានកាត់បន្ថយ គោលនយោបាយរូបិយវត្ថុរបស់ខ្លួនក្នុងការប្រឈមមុខនឹងអតិផរណាខ្ពស់។

យោងតាមការស្ទង់មតិរបស់ Reutersបានបញ្ជាក់ថាអត្រាប្រចាំឆ្នាំនៃកំណើនផលិតផលក្នុងស្រុកសរុបត្រូវបានរំពឹងថានឹងធ្លាក់ចុះមកត្រឹម ៤% នៅក្នុងត្រីមាសទី១នៃឆ្នាំ ២០២២ ដែលការរំពឹងទុក ៦% ក្នុងរយៈពេលបីខែចុងក្រោយនៃឆ្នាំនេះ។ ជារួមនៅឆ្នាំ ២០២២ ត្រូវបានគេមើលឃើញថាផ.ស.ស. ធ្លាក់ចុះដល់ -៣,៩%ប៉ុន្តែនៅតែល្អលើសពីនិន្នាការមុនការរាតត្បាត- ៥,៦% នៅឆ្នាំនេះ។

ធនាគារកណ្តាលនៃសហរដ្ឋអាមេរិកបានប្រកាសថា៖ ខ្លួននឹងបង្កើនល្បឿននៃការទិញសញ្ញាបណ្ណរបស់ខ្លួនទ្វេដងក្នុងការឆ្លើយតបទៅនឹងកំណើនការងាររឹងមាំ និងការកើនឡើងនៃអតិផរណាហើយបានបង្ហាញពីសញ្ញាថាវាអាចដំឡើងអត្រាការប្រាក់បីដងនៅឆ្នាំក្រោយ។ ប៉ុន្តែអ្នកសេដ្ឋកិច្ចលោក Zandi បាននិយាយថា វាអាចបង្ហាញពីការលំបាកសម្រាប់ធនាគារកណ្តាលសហរដ្ឋអាមេរិកក្នុងការចាប់ផ្តើមការដំឡើងអត្រាការប្រាក់ចំនួនបីដងប្រសិនបើកំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកយឺតជាងការរំពឹងទុកដំបូង។

ការរីករាលដាលនៃការឆ្លងជំងឺកូវីដ-១៩កំពុងចាប់ផ្តើមប៉ះពាល់ដល់អាជីវកម្មមួយចំនួននៅក្នុងទីក្រុងញូវយ៉ក និងកន្លែងផ្សេងទៀត ដែលនាំទៅដល់ការលុបចោលព្រឹត្តិការណ៍សំខាន់ៗ, ការបិទភោជនីយដ្ឋាន និងការពន្យាពេលដល់ផែនការត្រឡប់ទៅបំពេញការងារនៅការិយាល័យវិញ។ ផលប៉ះពាល់នៃ Omicron មិនទាន់អាចមើលឃើញនៅក្នុងសូចនាករប្រេកង់ខ្ពស់ដែល អាចបង្កឱ្យមានការធ្លាក់ចុះនៃការងារស្រដៀងនឹងអ្វីដែលបានឃើញនៅក្នុងខែធ្នូ ឆ្នាំ ២០២០៕

*ដោយ សេន ចន្ទី*

*ប្រភព៖reuters,ចេញផ្សាយថ្ងៃទី២១ខែធ្នូ ឆ្នាំ២០២១*

## ការខ្ចីប្រាក់របស់ចក្រភពអង់គ្លេសបានធ្លាក់ចុះពាក់កណ្តាល ខណៈដែលការចំណាយលើជំងឺរាតត្បាតកូវីដ-១៩មានសភាពធូរស្រាល



*ប្រភព៖ reuters, 2021 រូបភាព៖ Dado Ruvic/Illustration*

យោងតាមទិន្នន័យនៃការព្យាករណ៍សារជាថ្មីរបស់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៃចក្រភពអង់គ្លេស លោក Rishi Sunak បានបង្ហាញថា៖ ការខ្ចីប្រាក់របស់អង់គ្លេសបានធ្លាក់ចុះជិតពាក់កណ្តាលក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំសារពើពន្ធ២០២១ដែលជាការធ្លាក់ចុះកម្រិតខ្ពស់មួយពុំធ្លាប់មានក្រោយសង្គ្រាមលោកលើកទីពីរ និង ធ្លាក់ចុះខ្លាំងបន្ទាប់ពីកម្រិតការខ្ចីឆ្នាំមុនមានការកើនឡើង នៅពេលដែលសេដ្ឋកិច្ចប្រឈមមុខនឹងការរាតត្បាតពេញលេញនៃជំងឺរាតត្បាតកូវីដ-១៩។

ទន្ទឹមនឹងនេះលោកបានបន្តទៀតថាៈការខ្ចីប្រាក់ក្នុងឆ្នាំសារពើពន្ធ សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២ គឺស្ថិតនៅរង្វង់ប្រមាណ៤០ប៊ីលានផោន (៥៥ប៊ីលានដុល្លារ) ក្រោមការព្យាករណ៍ចុងក្រោយដែលបានធ្វើឡើងនៅក្នុងខែមីនា ដោយសារកំណើនសេដ្ឋកិច្ចលឿនជាងមុន។

សម្រាប់ការរៀបចំផែនការថវិកាឆ្នាំ២០២២ ត្រូវបានរំពឹងថានឹងកាត់បន្ថយការចំណាយសម្រាប់នាយកដ្ឋានរដ្ឋាភិបាលជាច្រើន បន្ទាប់ពីការកើនឡើងនៃការចំណាយលើជំងឺរាតត្បាតជាប្រវត្តិសាស្ត្រកាលពីឆ្នាំមុន។ ចំណែកឯការត្រួតពិនិត្យថវិកា និងការចំណាយផ្សេងៗនឹងកំណត់ពីរបៀបដែលយើងនឹងបន្តគាំទ្រសេវាកម្មសាធារណៈ, អាជីវកម្ម និងការងារខណៈពេលដែលរក្សាហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋឱ្យមានភាពសមស្របសម្រាប់អនាគត។

ឱនភាពថវិការបស់ចក្រភពអង់គ្លេសបានកើនឡើងរៀងរាល់ឆ្នាំដល់កម្រិតខ្ពស់បំផុតចាប់តាំងពីសង្គ្រាមលោកលើកទី ២នៅកម្រិត១៥% នៃផ.ស.ស. ប៉ុន្តែត្រូវ បានគេរំពឹងថានឹងធ្លាក់ចុះមកត្រឹមជាងពាក់កណ្តាលក្នុងឆ្នាំនេះដោយសារតែការបញ្ចប់នៃការគាំទ្រសេដ្ឋកិច្ចគ្រាអាសន្ននិងការប្រមូលប្រាក់ចំណូលពន្ធកាន់តែខ្លាំង។

អ្នកសេដ្ឋកិច្ចបាននិយាយថា ការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលគឺជាហានិភ័យសម្រាប់សេដ្ឋកិច្ច ដែលបន្ទាប់ពីការស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័សនៅក្នុងឆមាសទីមួយនៃឆ្នាំនេះនឹងបានធ្លាក់ចុះវិញគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានខែថ្មីៗនេះស្របពេលដែលករណីកូវីដ-១៩ ក៏ស្ទុះងើបឡើងវិញយ៉ាងខ្លាំង។

តាមរយៈការិយាល័យស្ថិតិជាតិរបស់អង់គ្លេសបានបញ្ជាក់ថាៈ ការខ្ចីមានបីកម្រិតមុនជួបវិបត្តិកូវីដ-១៩ គឺការខ្ចីប្រាក់ពីវិស័យសាធារណៈសម្រាប់រយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ ២០២១ បានធ្លាក់ចុះមកត្រឹម ១០៨,១ ប៊ីលានផោនគឺ ធ្លាក់ចុះចំនួន ១០១,២ប៊ីលានផោនពីខែមេសា ដល់ខែកញ្ញា ឆ្នាំ ២០២០ ប៉ុន្តែនៅតែមានចំនួនច្រើនជាងបីដងមុនពេលជំងឺរាតត្បាត។ សម្រាប់ខែកញ្ញាការខ្ចីប្រាក់សាធារណៈបានធ្លាក់ចុះមកនៅត្រឹម ២១,៧ប៊ី លានផោន (៣០,១ ប៊ីលានដុល្លារ) ទាបជាងបន្តិចនៃការព្យាករណ៍ដោយអ្នកសេដ្ឋកិច្ច ដែលមានចំនួន ២២,៦ប៊ីលានផោននៅក្នុងការស្ទង់មតិរបស់ Reuters ។

សម្រាប់ត្រួតពិនិត្យចុងក្រោយនៅខែសីហាត្រូវបានកែសម្រួលធ្លាក់ចុះជិត ៤ ប៊ីលានផោនដល់ ១៦,៨ ប៊ីលានផោនដែលឆ្លុះបញ្ចាំងពីចំណូលពន្ធសាជីវកម្មកាន់តែខ្លាំង និងការចំណាយទាបលើសេវាសាធារណៈ និងកម្មវិធីគាំទ្រការងារច្រើនជាងការប៉ាន់ស្មានដំបូង។

បើប្រៀបធៀបនឹងឆ្នាំមុន ចំណូលពន្ធក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះបានកើនឡើង២០%ខណៈដែលការចំណាយប្រចាំថ្ងៃទាបជាង ៦%។ កាលពីខែមុន រដ្ឋមន្ត្រីSunak បានប្រកាសពីការដំឡើងពន្ធចំនួន ១២ប៊ីលានផោនលើកម្មករ និងនិយោជកដែលចាប់ផ្តើមនៅឆ្នាំក្រោយ ដើម្បីផ្តល់មូលនិធិដល់ការថែទាំសុខភាព និងសង្គមនិងដើម្បីនាំយកថវិកាកាន់តែខិតទៅជិតសមតុល្យ។

ទិន្នន័យថ្មីៗបានបង្ហាញថាបំណុលសុទ្ធរបស់វិស័យសាធារណៈមានចំនួនសរុប ២,២ទ្រីលានផោន ស្មើនឹង ៩៥,៥% នៃផ.ស.ស. និងទាបជាងកម្រិតកំពូល នៃ ៩៦,៧% ក្នុងខែឧសភា និងមិថុនា ដែលជាចំនួនខ្ពស់បំផុតចាប់តាំងពីឆ្នាំ ១៩៦៣ ។ ស្របពេលដែលអត្រាការប្រាក់ទាបបំផុតបានរក្សាការចំណាយលើសេវាបំណុលនៅជិតកម្រិតទាបបំផុតរហូតមកដល់ ពេល

នេះភាគហ៊ុនដ៏ធំរបស់ចក្រភពអង់គ្លេសនៃសញ្ញាបណ្ណ ដែលភ្ជាប់ដោយសន្ទស្សន៍មានន័យថាវិក័យប័ត្រការប្រាក់ឥឡូវនេះកំពុងកើនឡើងនៅពេលដែលអតិផរណាកើនឡើង។ ការទូទាត់ការប្រាក់បានកើនឡើងត្រឹមតែជាង៥០%បើធៀបនឹងឆ្នាំមុន,ធនាគារកណ្តាលអង់គ្លេសបានផ្តល់សញ្ញាថាខ្លួនកំពុងឆ្ពោះទៅរកការដំឡើងអត្រាការប្រាក់ជាលើកដំបូងចាប់តាំងពីជំងឺរាតត្បាតរាតត្បាត៕ *ដោយ សេន ចន្ទី*

*ប្រភព៖financialpost,ចេញផ្សាយថ្ងៃទី២១ខែធ្នូ ឆ្នាំ២០២១*

## តម្លៃប្រេងឆៅធ្លាក់ចុះវិញភ្លាមៗ ក្រោយកំណើនករណីឆ្លងកូវីដ១៩អូមីក្រុង នៅអឺរ៉ុប និងនៅអាមេរិកហក់ឡើងខ្លាំង



*ប្រភព ៖ ខេមបូណ្ឌមីស*

តម្លៃប្រេងឆៅពិភពលោក នៅថ្ងៃដើមសប្តាហ៍នេះ បានធ្លាក់ចុះវិញភ្លាមៗ ដោយសារតែកូវីដ១៩បំប្លែងខ្លួន អូមីក្រុង ដែលកំពុងលុកលុយក្នុងប្រទេសជាច្រើននៅអឺរ៉ុប និងអាមេរិកផងដែរ។ ជាក់ស្តែងតម្លៃប្រេងអង់គ្លេសក្នុងមួយធុងបារ៉ែល ធ្លាក់ថ្លៃអស់ជាង១,៣០ដុល្លារស្មើនឹងជិត២%។ រីឯប្រេងឆៅរបស់អាមេរិកវិញ ធ្លាក់ចុះជាង ១,៥០ដុល្លារ ស្មើនឹង ២,១%។

អ្នកវិភាគផ្នែកទីផ្សារមកពីចក្រភពអង់គ្លេស បានឱ្យដឹងថា ការធ្លាក់ចុះតម្លៃប្រេងឆៅនៅដើមសប្តាហ៍នេះ ដោយសារតែ ក្តីបារម្ភពីការដាក់ចេញនូវវិធានការរឹតត្បិតសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីទប់ទល់នឹងកំណើនកូវីដ១៩អូមីក្រុង។ ការកម្រិតសកម្មភាពសេដ្ឋកិច្ច និងសង្គម នឹងឈានទៅធ្វើឱ្យតម្រូវការប្រើប្រាស់ប្រេងថយចុះ។ ជាក់ស្តែង ប្រទេសហូឡង់កាលពីសប្តាហ៍មុន បានប្រកាសពីការបិទខ្ទប់ប្រទេសចាប់ពីថ្ងៃអាទិត្យទី១៩ រហូតដល់ពាក់កណ្តាលខែមករា ឆ្នាំ២០២២ដើម្បីបញ្ចៀសរលកឆ្លងទី៥ ដោយអូមីក្រុងដែលឆ្លងលឿន និងឆ្លងខ្លាំង។ ដោយឡែក សហរដ្ឋអាមេរិកមិនបានបិទខ្ទប់ប្រទេស ឬដាក់ចេញវិធានការអ្វីឡើយ ទោះបីករណីឆ្លងថ្មីកំពុងកើនឡើងដល់ទៅ៥០%ក្តី ដោយគ្រាន់តែក្រើនរំឭកពលរដ្ឋ ពាក់ម៉ាស់ក្នុងទីសាធារណៈ និងនៅពេលធ្វើដំណើរក្នុងថ្ងៃឈប់សម្រាកខាងមុខ ព្រមទាំងបានជំរុញឱ្យគេទៅទទួលយកថ្នាំវ៉ាក់សាំងដូសជំរុញតែប៉ុណ្ណោះ។

តម្លៃប្រេងឆៅសកលត្រូវបានអ្នកជំនាញប៉ាន់ស្មានថានឹងបន្តធ្លាក់ថ្លៃបន្ថែមទៀត ប្រសិនបើប្រទេសកាន់តែច្រើន ផ្តើមដាក់ចេញវិធានការរឹតត្បិត ឬឈានដល់ការបិទខ្ទប់ប្រទេស ដែលធ្វើឱ្យតម្រូវការប្រេងថយចុះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។*

## ចិននាំមុខអាមេរិក ក្នុងកំពូលតំណែងជាប្រទេសមានទ្រព្យសម្បត្តិជាតិច្រើនជាងគេលើពិភពលោក




*ដោយ ខេមបូណ្ឌមីស*

ទ្រព្យសម្បត្តិសុទ្ធរបស់ចិនបានកើនឡើងដល់១២០ទ្រីលានដុល្លារអាមេរិកក្នុងឆ្នាំ២០២០ នាំមុខសហរដ្ឋអា

មេរិក។ ការកើនឡើងតម្លៃទ្រព្យសកម្មរបស់ចិននេះ ដោយសារតែការរីកចម្រើនយ៉ាងឆាប់រហ័ស ពិសេសគឺនៅលើវិស័យអចលនទ្រព្យដែលជាចន្ទល់ដ៏រឹងមាំសម្រាប់សេដ្ឋកិច្ចចិន។ បន្ថែមពីលើនេះ ប្រាក់មួយចំនួនដែលរដ្ឋាភិបាលចិនបានចាក់ចូលទៅក្នុងសេដ្ឋកិច្ច ដែលជាផ្នែកមួយនៃការឆ្លើយតបនឹងជំងឺរាតត្បាតកូវីដ១៩ បានហូរចូលទៅក្នុងទីផ្សារអចលនទ្រព្យផងដែរ។

របាយការណ៍ថ្មីមួយបានវាយតម្លៃពីទ្រព្យសម្បត្តិជាតិរបស់ប្រទេសធំៗចំនួន១០ តំណាងឱ្យជាង៦០%នៃចំណូលពិភពលោក។ ទ្រព្យសម្បត្តិជាតិសរុបសម្រាប់ក្រុមប្រទេសទាំងនេះ បានកើនឡើងបីដងគិតចាប់ពីឆ្នាំ២០០០ មកដល់ឆ្នាំ២០២០ ពោលគឺបានកើនឡើងដល់ទៅ៥១០ទ្រីលានដុល្លារ។ ប្រទេសចិនមានទ្រព្យសម្បត្តិជាតិសុទ្ធកើនឡើង១៧ដង ពីជាង៧ទ្រីលានដុល្លារនៅក្នុងឆ្នាំ២០០០ កើនដល់ជិត ១២០ទ្រីលានដុល្លារក្នុងឆ្នាំ២០២០ ដែលតំណាងឱ្យ២៣%នៃទ្រព្យសរុបពិភពលោក, អាមេរិកឈរលំដាប់ទី២ តំណាងឱ្យ១៧%មានទ្រព្យសរុប ៨៩ទ្រីលានដុល្លារ និងជប៉ុនតំណាងឱ្យជាង ៧% មានទ្រព្យសម្បត្តិជាតិសរុប ៣៥ទ្រីលានដុល្លារ។ ក្រុមប្រទេសធំៗទាំង១០ក៏រួមបញ្ចូលផងដែរនូវប្រទេសអាល្លឺម៉ង់ បារាំង កាណាដា អូស្ត្រាលី ចក្រភពអង់គ្លេស មិុចសិច និងប្រទេសស៊ុយអែត។

ទ្រព្យសម្បត្តិជាតិសុទ្ធ គឺសំដៅដល់តម្លៃនៃទ្រព្យសកម្មសរុបរដ្ឋ ដោយដកកម្រិតបំណុលចេញ៕ *ដោយ ម៉ែន ខែមរៈ ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។*

## IMF ព្រមានពីហានិភ័យនៃអត្រាការប្រាក់កម្ចី នៅពេលដែលបំណុលនៅទូទាំងសកលលោកកើនដល់ ២២៦ទ្រីលានដុល្លារ




*ដោយ ខេមបូណ្ឌមីស(អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ IMF)*

អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានលើកឡើងថា បំណុលនៅទូទាំងសកលលោក បានកើនឡើងដល់ទៅ២២៦ទ្រីលានដុល្លារអាមេរិកនៅឆ្នាំ ២០២០ ដែលជាចំនួនមួយច្រើនបំផុតមិនធ្លាប់មានគិតតាំងពីសម័យសង្គ្រាមលោកលើកទី២មក ដែលកំពុងបង្កហានិភ័យកាន់តែខ្លាំង ប្រសិនបើអត្រាការប្រាក់សកលលោកមានការកើនឡើងកាន់តែលឿនជាងអ្វីដែលបានរំពឹងទុក។ ការរាតត្បាតកូវីដ១៩ បង្កឱ្យបំណុលកើន ពោលគឺកើនឡើង២៨%បន្ថែមទៀតធៀបនឹងកម្រិតបំណុលដែលធ្លាប់មានពីមុន។ រដ្ឋាភិបាលនៃប្រទេសនានា វិស័យឯកជនក្នុងចំណោមសាជីវកម្មមិនមែនហិរញ្ញវត្ថុ និងគ្រួសារសុទ្ធតែមានបំណុលកើនដល់កម្រិតខ្ពស់បំផុតមួយផងដែរ។ ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ពិសេសប្រទេសចិន បានផ្តល់កម្ចីដល់ទៅ៩០%នៃកំណើនបំណុលសរុប ដោយសារមានអត្រាការប្រាក់ទាបសម្រាប់ប្រទេសទាំងនេះ។

អគ្គនាយកកិច្ចការសារពើពន្ធរបស់ IMFបានបញ្ជាក់ថាហានិភ័យនឹងមានកាន់តែខ្ពស់ ប្រសិនបើអត្រាការប្រាក់កើនឡើងខ្ពស់ជាងការរំពឹងទុក បង្កឱ្យមានក្តីបារម្ភអំពីចីរភាពបំណុលកាន់តែខ្លាំង។

បន្ថែមពីនេះ ការរឹតបន្តឹងកាន់តែខ្លាំងនៃលក្ខខណ្ឌហិរញ្ញវត្ថុ ក៏នឹងបង្កើនសម្ពាធកាន់តែធ្ងន់ធ្ងរទៅលើរដ្ឋាភិបាល ក្រុមគ្រួសារ និងក្រុមហ៊ុន ដែលកំពុងជំពាក់បំណុលនៅមិនទាន់សងរួចនៅទូទាំងពិភពលោកផងដែរ។ *ដោយ ម៉ែន ខែមវៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។*

## ទីផ្សារមាសឆ្នាំ២០២២ នឹងប្រែប្រួលយ៉ាងណាខ្លះ?



*ដោយ ខេមបូណ្ឌមីស*

អ្នកជំនាញមកពីក្រុមហ៊ុនYLGជាក្រុមហ៊ុនជួញដូរមាសដ៏ធំមួយប្រចាំនៅក្រុងបាងកកប្រទេសថៃ បានប៉ាន់ប្រមាណថា តម្លៃមាសនឹងនៅតែខ្ពស់ពេញមួយឆ្នាំ ២០២២ ស្របពេលដែលវិនិយោគិនព្យាយាមធ្វើយ៉ាងណាចៀសឱ្យផុតពីឥទ្ធិពលអតិផរណាពិភពលោក ដែលកំពុងកើនឡើង, ផលប៉ះពាល់សេដ្ឋកិច្ចពីមេរោគបំប្លែងថ្មី និងជម្លោះភូមិសាស្ត្រនយោបាយរវាងសហរដ្ឋអាមេរិក និងចិនជាដើម។ ប្រសិនបើស្ថានការណ៍ណាមួយក្នុងចំណោមស្ថានភាពទាំងបីខាងលើនេះកាន់តែអាក្រក់ឡើង នោះតម្លៃមាសពិភពលោកនឹងកើនឡើង។ នាយិកាប្រតិបត្តិក្រុមហ៊ុនជួញដូរមាស YLG បានលើកឡើងថា នៅក្នុងត្រីមាសទី១ ឆ្នាំ ២០២២ តម្លៃមាសទំនងជានឹងមានដល់ចន្លោះពី ១ ៨០០ ទៅ ១ ៩០០ ដុល្លារក្នុងមួយអោន។ តម្លៃមាសពិភពលោកគិតត្រឹមមួយសប្តាហ៍ចុងក្រោយនេះ មានជាមធ្យមជាង ១ ៧៩៦ ដុល្លារអាមេរិកក្នុងមួយអោន។ មានកត្តាចំនួន ៥ ទៀតដែរ ដែលទំនងជាអាចធ្វើឱ្យមានឥទ្ធិពលទៅលើតម្លៃទីផ្សារមាសនៅឆ្នាំក្រោយនេះគឺ ៖

កត្តាទី ១ គឺការសម្រេចចិត្តរបស់ធនាគារកណ្ដាលសហរដ្ឋអាមេរិក ក្នុងការបង្កើនល្បឿននៃការបន្ធូរបន្ថយ និងការកើនឡើងអត្រាការប្រាក់ ដើម្បីទប់ស្កាត់អតិផរណា ដែលនឹងធ្វើឱ្យតម្លៃមាសកើនឡើងបន្តិចនៅក្នុងត្រីមាសទី ១ឆ្នាំ២០២២ ប៉ុន្តែវានឹងមកធ្លាក់ចុះបន្តិចម្តងៗ។

កត្តាទី ២ គឺ ការបង្កើនការទិញមាសរបស់ធនាគារកណ្ដាល។ តួយ៉ាង ធនាគារកណ្ដាលថៃ និងស្ថាប័ន SPDR Gold Trust ដែលជាមូលនិធិមាសដ៏ធំបំផុត បានទិញមាសស្តុកទុកបន្ថែមទៀតក្នុងអំឡុងត្រីមាសចុងក្រោយក្នុងឆ្នាំនេះ ហើយនឹងបន្តទិញទៅឆ្នាំក្រោយទៀត។

កត្តាទី ៣ គឺ តម្រូវការមាសជាសកលក៏កំពុងស្ទុះងើបឡើងវិញ ជាពិសេសនៅក្នុងទីផ្សារចិន និងឥណ្ឌា ដែលសុទ្ធសឹងតែជាអ្នកនាំចូលមាសដ៏ធំបំផុតរបស់ពិភពលោក។

កត្តាទី ៤ គឺមាសជាប្រភេទលោហៈធាតុមានតម្លៃ ដែលជាទីពេញចិត្តរបស់អ្នកវិនិយោគ ព្រោះវាត្រូវបានគេចាត់ទុកថា ជាទ្រព្យសម្បត្តិដែលមានសុវត្ថិភាពបំផុតធៀបនឹងទ្រព្យសម្បត្តិផ្សេងទៀត។

កត្តាទី ៥ គឺ ទាក់ទងនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ FinTech ដែលនឹងអនុញ្ញាតឱ្យមនុស្សវិនិយោគលើមាស ដោយចំណាយប្រាក់តែបន្តិចបន្តួច គឺអ្នកទិញ ឬវិនិយោគិនអាចទិញមាសតាមអ៊ីនធឺណិតបានត្រឹមតែ ១០០បាត ឬជិត ៣ដុល្លារ ក្នុងទម្រង់នៃការសន្សំមាស។

បើតាមអ្នកជំនាញ សម្រាប់កត្តាដែលមានឥទ្ធិពលបំផុតទៅលើទីផ្សារតម្លៃមាសពិភពលោក នៅរយៈពេល

៣ខែទៅមុខទៀតនេះ គឺ បញ្ហាអតិផរណានៅអាមេរិក, បញ្ហាផលប៉ះពាល់សេដ្ឋកិច្ចដែលបណ្តាលមកពីមេរោគបំប្លែងថ្មីអូមីក្រុង និងបញ្ហាជម្លោះនយោបាយជាដើម។

*ដោយ ម៉ែន ខែមវរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១។*

## **ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់**

ថ្ងៃចន្ទ ទី២៧ ខែធ្នូ ឆ្នាំ២០២១

- សន្ទស្សន៍ទំនុកចិត្តផលិតកម្មនៅក្នុងប្រទេសទួរគីបានធ្លាក់ចុះ ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ការទាមទារគ្មានការងារធ្វើនៅប្រទេសបារាំងបានថយចុះ ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃអង្គារ ទី២៨ ខែធ្នូ ឆ្នាំ២០២១

- អត្រានិកម្មភាព របស់ប្រទេសជប៉ុនបានធ្លាក់ចុះ ក្នុងខែតុលា ឆ្នាំ 2021
- អតិរេកពាណិជ្ជកម្មនៅអាហ្វ្រិកខាងត្បូងបានរួមតូច ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃពុធ ទី២៩ ខែធ្នូ ឆ្នាំ២០២១

- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ក្នុងប្រទេសរុស្ស៊ីបានកើនឡើង 0.96 %នៅក្នុងខែវិច្ឆិកា ឆ្នាំ 2021 ធៀបនឹងខែមុន
- អត្រានិកម្មភាព របស់រុស្ស៊ីនៅតែមិនផ្លាស់ប្តូរនៅ 4.3%នៅក្នុងខែតុលា 2021 និងទាបជាងការព្យាករណ៍ទីផ្សារ 4.4%

ថ្ងៃព្រហស្បតិ៍ ទី៣០ ខែធ្នូ ឆ្នាំ២០២១

- អត្រាអតិផរណាតម្លៃទំនិញប្រើប្រាស់របស់អេស្ប៉ាញឈរនៅ 5.5%ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- GDP ប្រចាំខែ នៅក្នុងប្រទេសរុស្ស៊ីបានកើនឡើងដល់ 4.90% នៅក្នុងខែតុលាពី 3.70% នៅក្នុងខែកញ្ញានៃ 2021

ថ្ងៃសុក្រ ទី៣១ ខែធ្នូ ឆ្នាំ២០២១

- អតិផរណារបស់ប្រទេសកូរ៉េខាងត្បូងបានកើនឡើង 0.4% នៅក្នុងខែវិច្ឆិកា 2021
- ឱនភាពសារពើពន្ធរបស់ប្រទេសឥណ្ឌាបានរួមតូចដល់ ក្នុងខែមេសា ដល់ខែតុលា ឆ្នាំ 2021៕